សួស្តី នៅក្នុងរូបភាពនេះ គឺយើងនឹងនិយាយអំពីពិធីបុណ្យអុំទូក
ដែលឈ្មោះជាផ្លូវការនៃពិធីបុណ្យនេះ យើងហៅថា ព្រះរាជពិធីបុណ្យអុំទូកសំពះព្រះខែ
និងអកអំបុក អញ្ចឹងជាទូទៅប្រជាជនកម្ពុជាតែងតែហៅពិធីបុណ្យនេះជាភាសាកាត់
ដែលយើងហៅថា ពិធីបុណ្យអុំទូក ដែលពិធីបុណ្យអុំទូកគឺយើងតែងតែធ្វើនៅរដូវទឹកឡើង
ហើយការកំណត់ពេលវេលានៃពិធីបុណ្យអុំទូក គឺយើងកំណត់ទៅតាមពេលវេលានៃចន្ទគតិ
បានន័យថាការរាប់ប្រតិទិននៅក្នុងប្រទេសកម្ពុជា គឺមានពីរ អញ្ចឹងការរាប់ប្រតិទិននៅប្រទេសកម្ពុជា
គឺមានពីរ គឺមានតាមរយៈការរាប់តាមចន្ទគតិ និងរាប់តាមសុរិយគតិ អញ្ចឹងសុរិយគតិគឺមានខែចំនួន
១២ ដូចជាខែមករា ខែកុម្ភៈ ខែមីនា ខែមេសា ខែឧសភា ខែមិថុនា ខែកក្កដា ខែសីហា ខែកញ្ញា
ខែតុលា និងខែធ្នូ អញ្ចឹងមានចំនួន ១២ ហើយចំពោះថ្ងៃគឺមាន ៧ ដូចជា ថ្ងៃចន្ទ អង្គារ ពុធ
ព្រហស្បតិ៍ សុក្រ សៅរ៍ និងអាទិត្យ អញ្ចឹងនេះគឺជាការរាប់តាមសុរិយគតិ ក៏ប៉ុន្តែពិធីបុណ្យអុំទូក
គឺគេយកតាមចន្ទគតិ ដែលចន្ទគតិក៏មានខែចំនួន ១២ ដែរ ដូចជា មាឃ ខែបុស្ស ខែផល្គុន ខែមាឃ
ខែចេត្រ ខែពិសាខ ខែជេស្ឋ ខែអាសាឍ ខែស្រាពណ៍ ខែភទ្របទ ខែអស្សុជ និងខែកត្តិក
អញ្ចឹងមានចំនួន ១២ ហើយចំពោះការរាប់ថ្ងៃ គឺយើងប្រើប្រាស់ថ្ងៃកើត និងរនោច
អញ្ចឹងគឺយើងមានដូចជាថ្ងៃ ១ កើត ថ្ងៃ ២ កើត រហូតដល់ថ្ងៃ ១៥ កើត ជាមួយនឹងថ្ងៃ ១ រោច
រហូតដល់ថ្ងៃ ១៤ រោច ចំពោះពិធីបុណ្យអុំទូកគឺយើងធ្វើនៅខែអស្សុជ កត្តិក
ដែលជាទូទៅត្រូវនឹងខែវិច្ឆិកា ហើយថ្ងៃវិញ គឺថ្ងៃទី ១៤ កើត ថ្ងៃ ១៥ កើត និងថ្ងៃ ១ រោច
ដែលពិធីបុណ្យអុំទូកគឺយើងធ្វើរយៈពេលបីថ្ងៃនៅរដូវទឹកឡើង អញ្ចឹងរាប់តាមចន្ទគតិ គឺខែអស្សុជ
គឺយើងហៅថាខែទឹកឡើង ហើយជាទូទៅខែអស្សុជ គឺត្រូវជាមួយនឹងខែវិច្ឆិកា គឺខែ ១១

អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញ មើលរូបភាពទី ១ នៅក្នុងរូបភាពទី ១
គឺយើងឃើញមានរូបភាពជាទន្លេមួយ ដែលជាទូទៅគឺយើងហៅថាទន្លេសាប
អញ្ចឹងនៅក្នុងប្រទេសកម្ពុជាមានបឹងមួយយ៉ាងធំ គឺយើងហៅថាបឹងទន្លេសាប ដែលបឹងនេះ
គឺជាបឹងប្រវត្តិសាស្ត្រមួយ ដែលមានអាយុកាលរាប់រយឆ្នាំមកហើយ ហើយបឹងនេះ
គឺមានលក្ខណៈចម្លែក ហើយនៅក្នុងរូបភាពនេះ គឺយើងឃើញមានមេឃពពកខ្មៅយ៉ាងក្រាស់
នៅពីលើទេសភាពពណ៌បៃតង អញ្ចឹងបានន័យថាជារដូវភ្លៀង
ដោយយើងឃើញភ្លៀងបង្អុរធ្លាក់មកយ៉ាងខ្លាំង ទៅលើស្រោចស្រពទៅលើដំណាំ
ក៏ដូចជាទេសភាពពណ៌បៃតង ដែលយើងឃើញនៅខាងក្រោមនោះគឺយើងឃើញ មានដើមឈើ
មានភ្នំ ហើយមានភ្នំតូចធំ មានដើមឈើតូចធំជាច្រើន ដែលដុះអមនៅតាមសងខាងនៃដងទន្លេ
អញ្ចឹងនៅកណ្តាល យើងឃើញមានទឹកទន្លេហូរ ដែលយើងឃើញសញ្ញាព្រួញ
គឺហូរពីឆ្វេងទៅខាងស្តាំ អញ្ចឹងបានន័យថាទឹកទន្លេកំពុងតែហូរពីឆ្វេងទៅខាងស្តាំ
ដោយជាទូទៅរដូវវស្សា គឺទឹកបឹងទន្លេសាប គឺតែងតែហូរចាក់ចូលទៅក្នុងទន្លេមេគង្គ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងនៅក្នុងប្រទេសកម្ពុជាគឺមានទន្លេធំៗចំនួនពីរ ដែលទីមួយយើងហៅថាបឹងទន្លេសាប
គឺជាបឹងចំណាស់ដែលមានអាយុកាលរាប់រយឆ្នាំមកហើយនៅក្នុងប្រទេសកម្ពុជា ចំណែកឯទន្លេទីពីរ
គឺជាទន្លេមេគង្គ ដែលជាទន្លេធំជាងគេនៅក្នុងប្រទេសកម្ពុជា ដែលទន្លេមួយនេះ
គឺហូរមកពីប្រទេសចិន កាត់ប្រទេសថៃ កាត់ប្រទេសឡាវ កាត់ប្រទេសកម្ពុជា
និងកាត់ប្រទេសវៀតណាម អញ្ចឹងនៅខែវស្សា នៅរដូវវស្សា គឺទឹកឡើង យើងហៅថាទឹកឡើង
បានន័យថាខែអស្សុជ អញ្ចឹងទឹកឡើងខ្ពស់ ទឹកឡើងខ្ពស់ នោះ ពេលនោះ
ទឹកនឹងពេញព្រៀបនៅទន្លេសាប ដោយសារតែជំនន់ទឹកភ្លៀង អញ្ចឹងនៅពេលដែលភ្លៀងខ្លាំង
គឺទឹកទន្លេសាបគឺឡើងខ្ពស់ ធ្វើឲ្យវាហៀរ អញ្ចឹងនៅពេលដែលទឹកទន្លេសាបឡើងខ្ពស់ហៀរចេញ
គឺទឹកទន្លេសាបនឹងហូរចាក់ចូលទៅក្នុងទឹកទន្លេមេគង្គ អញ្ចឹងទន្លេសាបនិងទន្លេមេគង្គ គឺជាប់គ្នា
គឺហូរចូលគ្នា ដូច្នេះនៅពេលដែលទន្លេសាបឡើងខ្ពស់
ទឹកទន្លេសាបនឹងហូរទៅចូលទៅដល់ទឹកទន្លេមេគង្គ អញ្ចឹងនៅក្នុងរូបភាពនេះ គឺជារដូវវស្សា
ដែលរដូវវស្សានៅក្នុងប្រទេសកម្ពុជា គឺមានចំនួន ៦ ខែ អញ្ចឹងរយៈពេល ៦ ខែនេះ
គឺទឹកភ្លៀងយ៉ាងខ្លាំង ធ្វើឲ្យមានជំនន់ទឹកភ្លៀងដែលធ្វើឲ្យទន្លេសាបពេញ
និងហៀរចាក់ចូលទៅទន្លេមេគង្គ ហើយរដូវវស្សាធ្វើឲ្យមាន រុក្ខជាតិមានពណ៌បៃតង
ដោយសារតែរុក្ខជាតិត្រូវការទឹក ដូច្នេះនៅពេលដែលមានភ្លៀង គឺធ្វើឲ្យរុក្ខជាតិពណ៌បៃតង
ហើយជាពិសេសកសិករគឺគាត់ធ្វើស្រែនៅក្នុងរដូវវស្សា ដោយសារតែជាទូទៅដំណាំស្រូវគឺត្រូវការទឹក
អញ្ចឹងហើយនៅពេលដែលរដូវវស្សាគឺជារដូវដែលមានសារសំខាន់
សម្រាប់ការធ្វើស្រែចំការរបស់ប្រជាកសិករ អ្នកដែលធ្វើស្រែយើងហៅថាកសិករ
អញ្ចឹងនៅកម្ពុជាគឺជាប្រទេសដែលពឹងផ្អែកលើរបបកសិកម្ម ដូច្នេះហើយប្រជាកសិករទាំងអស់
គាត់តែងតែរង់ចាំនូវរដូវវស្សា ដើម្បីប្រកបរបរកសិកម្មរបស់គាត់ ដើម្បីធ្វើដំណាំដាំដុះជាដើម
ព្រោះរដូវវស្សាគឺសម្បូរទឹក ហើយប្រទេសកម្ពុជាគឺធ្វើស្រែពឹងផ្អែកលើទឹកភ្លៀង
ដូច្នេះហើយរដូវភ្លៀងគឺមានសារសំខាន់ខ្លាំងណាស់។

បន្ទាប់មកទៀតរូបភាពទី ២ រូបភាពទី ២ យើងឃើញមានព្រះអាទិត្យរះ ជាមួយនឹងពពកពណ៌ស
បានន័យថាផ្ទៃមេឃស្រទ្បះ គឺអត់មានភ្លៀងទេ អញ្ចឹងចូលដល់រដូវប្រាំង អញ្ចឹងបានន័យថារដូវប្រាំង
គឺអត់មានភ្លៀងទេ ដោយសារតែរដូវចែកចេញជាពីរ គឺរដូវវស្សា និងរដូវប្រាំង
ដែលរដូវប្រាំងគឺអត់មានភ្លៀង រដូវវស្សាគឺមានភ្លៀង
អញ្ចឹងនៅក្នុងរដូវប្រាំងគឺយើងឃើញមានផ្ទៃមេឃស្រទ្បះ ពពកពណ៌ស
ហើយមានព្រះអាទិត្យកំពុងតែរះ បញ្ចេញរស្មីយ៉ាងភ្លឺចិញ្ចែងចិញ្ចាំងមកលើធម្មជាតិ អញ្ចឹងយើង
នៅក្នុងរូបភាពនេះ យើងឃើញមានរុក្ខជាតិពណ៌បៃតងតូចធំជាច្រើន និងមានភ្នំ មានទឹកទន្លេ
ហើយនិងមានព្រៃឈើនៅអមសងខាងទន្លេ ក៏ប៉ុន្តែទន្លេនៅពេលនេះ គឺហូរបញ្ច្រាសវិញ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺទឹកទន្លេគឺហូរពីស្ដាំមកឆ្វេង អញ្ចឹងរូបភាពនេះ គឺបញ្ជាក់អំពីផ្ទៃបឹងទន្លេសាប
ដែលបឹងទន្លេសាបគឺខែវស្សា ឬរដូវវស្សា គឺទឹកទន្លេសាបហូរចាក់ចូលទៅក្នុងទឹកទន្លេមេគង្គ
ចំណែកឯរដូវប្រាំង រដូវប្រាំងគឺជារដូវទឹកសម្រក អញ្ចឹងបានន័យថាទឹកស្រក
យើងអាចហៅថាទឹកស្រក ឬក៏រដូវសម្រក រដូវសម្រកបានន័យថាស្រក
អញ្ចឹងនៅពេលដែលរដូវសម្រកគឺទឹកទន្លេសាបគឺស្រកចុះ បានន័យថាអត់ខ្ពស់ដូចរដូវវស្សាទេ
មកពីអត់ភ្លៀង អញ្ចឹងនៅពេលដែលទឹកនៅក្នុងទន្លេសាបស្រកចុះ គឺទឹកនឹងទាបជាងទន្លេមេគង្គ
ដូច្នេះនៅពេលដែលទឹកទន្លេសាបទាបជាងទន្លេមេគង្គ ទឹកទន្លេមេគង្គនឹងហូរចាក់ចូលទន្លេសាបវិញ
អញ្ចឹងបឹងទន្លេសាបនិងបឹងទន្លេមេគង្គនេះគឺមានលក្ខណៈពិសេស
ខុសពីទន្លេដទៃដែលនៅប្រទេសផ្សេង បានន័យថាបឹងទន្លេសាបនៅប្រទេសកម្ពុជា
គឺមានលក្ខណៈពិសេស ខុសពីទន្លេដទៃដែលនៅប្រទេសផ្សេង
ដោយសារតែវាអាចហូរត្រលប់ទៅមកបាន គឺរដូវវស្សាហូរចាក់ចូលទៅទន្លេមេគង្គ
ចំណែកឯរដូវប្រាំងគឺទន្លេមេគង្គហូរចាក់ចូលទៅទន្លេសាបវិញ
បានន័យថាហូរទៅមកៗជារៀងរាល់ឆ្នាំ គឺលក្ខណៈពិសេសបែបនេះហើយ
ទើបធ្វើឲ្យបឹងទន្លេសាបគឺជាបឹងពិសេសមួយនៅក្នុងប្រទេសកម្ពុជា។

បន្ទាប់មកទៀតរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ គឺជារូបភាពដែលនិយាយអំពីព្រះចន្ទពេញបូណ៌មី
អញ្ចឹងនៅពេលដែលយើងមើលឃើញព្រះចន្ទរាងមូល ព្រះចន្ទមានរាងមូល
យើងហៅថាខែពេញបូណ៌ ថ្ងៃពេញបូណ៌ ឬក៏យើងហៅភាសាមួយទៀតយើងហៅថា ខែពេញបូណ៌មី
អញ្ចឹងខែពេញបូណ៌មីគឺជាថ្ងៃដែលព្រះចន្ទមានរាងមូល និងបញ្ចេញពន្លឺយ៉ាងស្រស់ស្អាត
ដែលត្រូវនឹងថ្ងៃ ១៥ កើត អញ្ចឹងបើយើងរាប់តាមប្រតិទិនចន្ទគតិ យើងហៅថាថ្ងៃ ១៥ កើត
គឺថ្ងៃពេញបូណ៌មី អញ្ចឹងព្រះចន្ទនឹងមានរាងមូល ដោយ ១៥ កើត បានន័យថាព្រះចន្ទកើត
អញ្ចឹងពីថ្ងៃ ១ កើត រហូតដល់ថ្ងៃ ១៥ កើត ថ្ងៃ ១ កើត គឺព្រះចន្ទមានរាងតូច
មានរាងតែមួយចំណិតតូច ដែលយើងមើលស្ទើរតែមិនឃើញ
ហើយព្រះចន្ទចាប់ផ្ដើមរីកមាឌរបស់ខ្លួនបន្តិចម្ដងៗ រយៈពេល ១៥ ថ្ងៃ បានន័យថាពីថ្ងៃ ១ កើត ២
កើត ៣ កើត ៤ កើត ៥ កើត ៦ កើត ៧ កើត ៨ កើត ៩ កើត រហូតដល់ថ្ងៃ ១៥ កើត
គឺព្រះចន្ទនឹងមានរាងមូលពេញវង់តែម្ដង យើងហៅថាព្រះចន្ទពេញវង់ ឬក៏ថ្ងៃពេញបូណ៌
ឬក៏ព្រះចន្ទពេញបូណ៌មី អញ្ចឹងនៅថ្ងៃព្រះចន្ទពេញបូណ៌មីគឺជាថ្ងៃសីល អញ្ចឹងមនុស្សម្នានាំគ្នាទៅវត្ត
ដើម្បីប្រគេនចង្ហាន់ដល់ព្រះសង្ឃ ដែលយើងឃើញនៅក្នុងរូបភាពនេះ គឺមានមនុស្សជាច្រើន
កំពុងតែទៅវត្ត ក៏ប៉ុន្តែវាគឺជាពេលយប់ អញ្ចឹងជាទូទៅការទៅវត្តនៅថ្ងៃពេញបូណ៌
គឺយើងទៅពេលព្រឹក គឺយើងអត់ទៅពេលយប់ទេ ក៏ប៉ុន្តែដោយសារថ្ងៃនេះ គឺជាថ្ងៃពិសេស
គឺជាថ្ងៃព្រះរាជពិធីបុណ្យអុំទូក ឬគឺថ្ងៃបុណ្យអុំទូក ដូច្នេះនៅពេលយប់គឺជាពេលវេលាមួយ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលមានមនុស្សកុះករទៅវត្ត នៅពេលដែលព្រះចន្ទពេញបូណ៌មី
ដោយយើងឃើញនៅក្នុងរូបភាពនេះ គឺជាពេលយប់ ដែលមានព្រះចន្ទពេញបូណ៌មីកំពុងតែរះ
ហើយមានមនុស្សជាច្រើន មានប្រុសស្រី ក្មេងចាស់ កំពុងតែដើរទៅវត្ត ហើយនៅជុំវិញវត្ត
ទៅសំពះព្រះនៅក្នុងព្រះវិហារ ដោយសារតែថ្ងៃពេញបូណ៌មីនៅក្នុងថ្ងៃអុំទូក
គឺយើងត្រូវប្រារព្ធពិធីសំពះព្រះខែ អញ្ចឹងនៅក្នុងរូបភាពទី ៣ នេះ
គឺប្រជាជនកំពុងតែនាំគ្នាទៅធ្វើពិធីសំពះព្រះខែនៅក្នុងព្រះវិហារនៅឯវត្ត។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញមានដៃមួយគូ ដៃឆ្វេងមួយ ដៃស្តាំមួយ
ដោយដៃម្ខាងកំពុងតែកាន់ធូប ដៃម្ខាងកំពុងតែកាន់ដែកកេះដើម្បីអុជធូប អញ្ចឹងនៅក្នុងថ្ងៃសីល
ឬក៏ថ្ងៃពេញបូណ៌ យើងតែងតែទៅវត្តដើម្បីអុជធូប អញ្ចឹងការអុជធូបគឺជាវប្បធម៌
ឬក៏ប្រពៃណីមួយរបស់អ្នកកាន់ព្រះពុទ្ធសាសនា ដោយអ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់
ត្រូវតែអុជធូប ដើម្បីឧទ្ទិសកុសលចំពោះអ្នកដែលបានស្លាប់ទៅ អញ្ចឹងនៅក្នុងព្រះពុទ្ធសាសនា
គឺយើងអុជធូបដើម្បីរំលឹកគុណទៅដល់អ្នកដែលបានស្លាប់ ដោយយើងអុជធូបនៅវត្តក៏បាន
នៅផ្ទះក៏បាន នៅពេលដែលយើងចង់សែនចង្ហាន់ ឬក៏សែនចំណីអាហារទៅឲ្យអ្នកស្លាប់
គឺយើងគ្រាន់តែអុជធូបនិងនិយាយឈ្មោះគេ គឺជាការស្រេច នោះចង្ហាន់នោះនឹងអាចដល់អ្នកស្លាប់
ដើម្បីញ៉ាំ នេះគឺជាជំនឿនៅក្នុងព្រះពុទ្ធសាសនា ដែលជាក់ស្តែងនៅក្នុងរូបភាពទី ៤ នេះ
យើងឃើញគេកំពុងតែអុជធូប មនុស្សកំពុងតែអុជធូប
ហើយគេនឹងបន់ស្រន់សូមបំណងប្រាថ្នាផ្សេងៗ ដើម្បីឲ្យសម្រេចបំណងប្រាថ្នារបស់គេ
បន្ទាប់មកគេដោតធូបចូលទៅក្នុងក្អម ឬក៏ឆ្នាំងដី ឬក៏ជើងកំប៉ុងជើងធូប ដែលនៅក្នុងរូបភាពនេះ
គេយកក្អម ឬក៏យកឆ្នាំងដីមកធ្វើជាកំប៉ុងជើងធូប ដោយយើងឃើញក្អម ឬក៏ឆ្នាំងដីចំនួនពីរ
ហើយមានធូបយ៉ាងច្រើនសរសៃនៅក្នុងនោះ អញ្ចឹងធូបមួយដើម គេរាប់ថាសរសៃ
អញ្ចឹងយើងឃើញធូបជាច្រើនសរសៃ កំពុងតែដោតនៅក្នុងក្អម ឬក៏ឆ្នាំងដី
ដែលបានន័យថាមានមនុស្សជាច្រើនបានមកអុជធូប ដើម្បីផ្សង ឬក៏ប៉ងនូវបំណងប្រាថ្នាផ្សេងៗ
ដើម្បីឲ្យបានសម្រេចនៅក្នុងថ្ងៃពេញបូណ៌មីនៅក្នុងថ្ងៃបុណ្យអុំទូកនេះ។

បន្ទាប់មកទៀតរូបភាពទី ៥ នៅក្នុងរូបភាពទី ៥ គឺយើងឃើញមានមនុស្សកំពុងតែអុជទៀន
អញ្ចឹងនៅក្នុងថ្ងៃបុណ្យអុំទូក ថ្ងៃពេញបូណ៌មី គឺយើងជាទូទៅនៅតាមវត្តអារាមនានា
គេតែងតែធ្វើពិធីអុជទៀន គឺដើម្បីបំភ្លឺ និងដើម្បីសម្រក់ទៀនទៅរកប្រផ្នូលផ្សេងៗផងដែរ
ដែលនៅក្នុងរូបភាពនេះ គេកំពុងតែអុជទៀតចំនួនបីដើម ដែលទៀន
ជាទូទៅទៀនគឺយើងធ្វើឡើងអំពីក្រមួន អញ្ចឹងក្រមួន គឺលក្ខណៈទន់ ហើយនៅពេលដែលត្រូវថ្ងៃ
គឺទន់រលាយ ប៉ុន្តែនៅពេលដែលត្រជាក់ គឺវាកករឹងឡើងវិញ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងទៀនជាទូទៅគឺយើងមានបណ្តូលកណ្តាលមួយ យើងហៅថាបញ្ឆេះ
អញ្ចឹងបញ្ឆេះទៀនគឺជាសរសៃអំបោះមួយ ដែលនៅចំកណ្តាលដងខ្លួននៃទៀន
ហើយគេដុតសរសៃអំបោះនោះ ដើម្បីបំភ្លឺ អញ្ចឹងនៅក្នុងរូបភាពនេះ គេយកទៀនមួយ
ហើយទៀនដែលកំពុងតែឆេះនោះ គេយកទៅអុជនៅទៀនមួយទៀត
បានន័យថាគេ[យកទៀននោះ]កំពុងតែបន្តភ្លើង អញ្ចឹងគេបន្តភ្លើងពីទៀនមួយទៅទៀនមួយ
ដើម្បីអុជបំភ្លឺគ្រប់ទៀនទាំងអស់ចំនួនបីដើម ហើយដើម្បីធ្វើពិធីផ្សេងៗនៅក្នុងថ្ងៃបុណ្យអុំទូក
ឬក៏ថ្ងៃពេញបូណ៌មី នៅក្នុងថ្ងៃបុណ្យអុំទូក ដើម្បីផ្សងនូវប្រផ្នូលផ្សេងៗ ដែលមាននៅក្នុងឆ្នាំនេះ
អញ្ចឹងពិធីបុណ្យអុំទូក គេត្រូវធ្វើការផ្សងប្រផ្នូលនានា ដើម្បីទាយឲ្យដឹងថា
តើឆ្នាំនេះនឹងមានអ្វីកើតឡើង ឆ្នាំនេះសម្បូរអ្វីខ្លះជាដើម ដែលជាក់ស្តែងនៅក្នុងរូបភាពនេះ
គឺយើងឃើញមនុស្សកំពុងតែអុជទៀន។

បន្ទាប់មករូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញទៀនកំពុងតែស្រក់
ហើយក្រមួនទៀនកំពុងតែស្រក់ចុះនៅលើស្លឹកចេក អញ្ចឹងគឺជាពិធីសម្រក់ទៀន
ដើម្បីផ្សងប្រផ្នូលនៅក្នុងវត្តអារាម អញ្ចឹងជាទូទៅប្រពៃណីខ្មែរ
បានន័យថាវប្បធម៌ខ្មែរនៅក្នុងពិធីបុណ្យអុំទូកនៅថ្ងៃទី ២ គឺយើងតែងតែធ្វើពិធីសម្រក់ទៀន
ដើម្បីផ្សង ឬក៏ដើម្បីចង់ដឹងអំពីប្រផ្នូលផ្សេងៗ ដែលកើតឡើងនៅក្នុងឆ្នាំនីមួយៗ
នៃការធ្វើពិធីបុណ្យអុំទូកនេះ ដោយជាទូទៅពិធីសម្រក់ទៀន គឺគេធ្វើឡើងដូចជាយកទៀនមួយដើម
ឬក៏ច្រើនដើម ចងផ្តោបចូលគ្នា បន្ទាប់មកគេដុតទៀនទាំងនោះឲ្យឆេះឡើង
ដោយអុជបញ្ឆេះទៀនឲ្យឆេះមានពន្លឺភ្លឺឡើង បន្ទាប់មកគេដាក់ទៀននោះនៅលើស្លឹកចេក
ឬក៏ធាងចេក អញ្ចឹងគេយកធាងចេក ឬក៏ស្លឹកចេកមកទ្រាប់នៅលើទៀន
ហើយនៅពេលដែលទៀនឆេះ គឺតែងតែសម្រកក្រមួនទៀន
អញ្ចឹងក្រមួនទៀននឹងធ្លាក់ចូលទៅលើស្លឹកចេក ឬក៏ធ្លាក់លើស្លឹកចេក អញ្ចឹងនៅពេលដែល
នៅពេលដែលក្រមួនទៀនធ្លាក់ គឺវារៀងរាវ ដូច្នេះហើយក្រមួនទៀននឹងចេញជារូបរាងផ្សេងៗ
ទៅតាមរូបរាងនូវស្លឹកចេក បានន័យថានៅពេលដែលវាធ្លាក់លើស្លឹកចេក វានឹងចេញរូបរាងផ្សេងៗ
ហើយរូបរាងទាំងនោះ គឺត្រូវបានអាចារ្យ ឬក៏ព្រះសង្ឃគាត់នឹងទស្សទាយ
គាត់នឹងទស្សទាយរូបរាងទាំងនោះថាដូចទៅជាអ្វី ដូច្នេះនៅពេលដែលក្រមួនទៀនកកហើយ
នោះវានឹងចេញជារូបរាងផ្សេងៗ អញ្ចឹងអាចារ្យ ឬក៏ព្រះសង្ឃ
គាត់នឹងទស្សទាយរូបភាពនោះថាតើឆ្នាំនេះនឹងមានអ្វីកើតឡើងនៅក្នុងស្រុក ឬនៅក្នុងប្រទេស
ដោយតើមានផលដំណាំបានផលដែរឬទេ ឬក៏តើប្រទេសនឹងជួបសេចក្តីសុខ
ឬក៏មានបញ្ហាអ្វីដែរឬទេ នៅក្នុងស្រុកភូមិមានបញ្ហា ឬមានជំងឺឈឺថ្កាត់អ្វីដែរឬទេ
អញ្ចឹងគេទស្សទាយទៅតាមរូបភាពនៃក្រមួនទៀនដែលបានស្រក់

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះហើយពិធីសម្រក់ទៀននៅក្នុងពិធីបុណ្យអុំទូក គឺមានសារសំខាន់ខ្លាំងណាស់ សម្រាប់ប្រជាជនខ្មែរ។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញមានដូង មានចេក មានអំបុក អញ្ចឹងយើងហៅថាពិធីអកអំបុក អញ្ចឹងនៅក្នុងពិធីបុណ្យអុំទូក គេធ្វើឡើងបីថ្ងៃ ដោយថ្ងៃទី ១ គឺយើង គឺជាថ្ងៃអុំទូក ឬក៏ថ្ងៃពិធីប្រណាំងទូក បន្ទាប់មកថ្ងៃទី ២ គឺជាថ្ងៃពេញបូណ៌ គេហៅថាថ្ងៃសំពះព្រះខែ អញ្ចឹងប្រជាជនទៅសំពះព្រះខែនៅតាមវត្តអារាម ហើយថ្ងៃទី ៣ គឺជាថ្ងៃអកអំបុក អញ្ចឹងជាទូទៅអំបុកគឺជាប្រភេទនំម្យ៉ាង ដែលកើតចេញអំពីស្រូវ អញ្ចឹងគេយកស្រូវថ្មី គេយកស្រូវដែលទើបតែច្រូតថ្មីៗទៅលីង អញ្ចឹងគេលីងស្រូវដែលទើបតែច្រូតថ្មីៗនៅក្នុងក្អម ឬក៏ឆ្នាំងដីមួយ ប៉ុន្តែគេលីងអត់ឲ្យឆ្អិនពេកនោះទេ នៅពេលដែលលីងស្រូវទាំងនោះរួចហើយ គេចាក់ស្រូវដែលលីងរួចចូលទៅក្នុងត្បាល់មួយ។ បន្ទាប់មកគេយកអង្រែមកដាល់ មកបុកត្បាល់នោះ ឲ្យគ្រាប់ស្រូវទាំងនោះបែកទៅជាបន្ទះស្តើងៗ អញ្ចឹងគ្រាប់អង្ករដែលនៅក្នុងស្រូវ គឺនឹងត្រូវសំប៉ែតទៅជាបន្ទះស្តើងៗដែលយើងហៅថាអំបុក អញ្ចឹងការធ្វើអំបុក គេហៅថាដាល់អំបុក គឺយើងអត់ហៅថាបុកអំបុកទេ គឺយើងហៅថាដាល់អំបុក អញ្ចឹងគេយកអំបុកដែលដាល់រួចហើយយកមករែង ដើម្បីយកអង្កាមចេញ អញ្ចឹងយើងអត់ញ៉ាំទាំងសំបកស្រូវទេ អំបុកគឺយើង នៅពេលដែលបុកនៅក្នុងត្បាល់រួចហើយ គឺយើងយកមករែងដោយចង្អេរ គឺយើងប្រើចង្អេរ ដើម្បីរែងនូវសំបកស្រូវឲ្យចេញពីអំបុកទាំងអស់ អញ្ចឹងនៅពេលដែលយើងរែង សំបកស្រូវគឺត្រូវខ្ចាតចេញមកក្រោម ហើយគ្រាប់អង្ករដែលឆ្អិនដែលសំប៉ែត នឹងនៅលើចង្អេរដែលយើងហៅថាអំបុក អញ្ចឹងអំបុក គឺជាទូទៅប្រជាជនកម្ពុជាតែងតែញ៉ាំជាមួយនឹងទឹកដូង សាច់ដូង និងជាមួយចេក ដែលជាក់ស្តែងនៅក្នុងរូបភាពទី ៧ នេះ យើងឃើញមានដូង និងមានចេក ដែលគេទុកប្រើប្រាស់ញ៉ាំជាមួយអំបុក អញ្ចឹងការញ៉ាំអំបុកភាគច្រើនគេអក ដែលយើងចាប់អំបុកមួយដៃ បានន័យថាយើងក្ដាប់អំបុកនៅក្នុងបាតដៃរបស់យើង បន្ទាប់មកយើងងើយមុខឡើងលើ ហើយហាមាត់ រួចហើយយើងទម្លាក់អំបុកចូលទៅក្នុងមាត់ ដែលយើងហៅថាអកអំបុក អញ្ចឹងពិធីនេះ គេហៅថាពិធីអកអំបុក ហើយជាទូទៅនៅក្នុងប្រទេសកម្ពុជា នៅពេលដែលអកអំបុក គឺយើងអត់អកខ្លួនឯងទេ គឺយើងតែងតែឲ្យអ្នកដទៃអកអំបុកឲ្យយើង បានន័យថាអ្នកដទៃបញ្ចុកអំបុកយើង អញ្ចឹងយើងហាមាត់ ហើយបងប្អូនរបស់យើងជាអ្នកបញ្ចុកអំបុកយើងដាក់ចូលក្នុងមាត់ ហើយបន្ទាប់មកយើងញ៉ាំទឹកដូង ឬក៏ញ៉ាំសាច់ដូង ឬក៏ញ៉ាំចេកជាមួយ ដែលជាទូទៅអំបុកគឺមានរសជាតិឆ្ងាញ់ និងមានស្រួយ និងស្រួយ លក្ខណៈស្រួយ អំបុកគឺមានស្រួយ អញ្ចឹងគេញ៉ាំជាមួយដូងនិងជាមួយចេក។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ គឺជារូបភាពនៃការប្រណាំងទូក
អញ្ចឹងជាទូទៅប្រណាំងទូកគឺធ្វើឡើងនៅក្នុងរាជធានីភ្នំពេញ អញ្ចឹងនៅក្នុងថ្ងៃបុណ្យអុំទូក
រយៈពេលបីថ្ងៃ គឺមានទូកជាច្រើន ដែលមកកុះករនៅក្នុងមាត់ទន្លេ យើងហៅថាទន្លេចតុមុខ
អញ្ចឹងទន្លេចតុមុខគឺជាទន្លេដែលមានមុខបួន ដែលមានន័យថាមានទន្លេបួន
ជួបគ្នានៅខាងមុខព្រះបរមរាជវាំង អញ្ចឹងទន្លេដែលនៅព្រះបរមរាជវាំង
នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសកម្ពុជា គឺមានលក្ខណៈពិសេសខុសគេដែរ
ដោយសារតែទន្លេបួន គឺជួបគ្នានូវខាងមុខព្រះបរមរាជវាំង ដែលយើងហៅថាទន្លេចតុមុខ
ដែលទន្លេប្រភេទនេះគឺអត់ដែលមាននៅក្នុងពិភពលោកទេ
គឺមានតែនៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ ដែលមានទន្លេបួនជួបគ្នានៅទីតាំងមួយ ហើយទីតាំងនោះ
គេបានសាងសង់ជាព្រះបរមរាជវាំង ដែលជាកន្លែងដែលព្រះមហាក្សត្រស្នាក់នៅ
អញ្ចឹងជារៀងរាល់ឆ្នាំ នៅរដូវទឹកឡើង គេតែងតែប្រារព្ធពិធីបុណ្យអុំទូកនៅខាងមុខព្រះបរមរាជវាំង
ដោយមានទូកងជាច្រើនមកតម្រៀបត្រៀបត្រា ដើម្បីប្រណាំងគ្នា អញ្ចឹងទូកប្រណាំង
យើងហៅថាទូកង ដោយទូកប្រណាំងមានច្រើនប្រភេទ ដូចជាទូកអុំ និងទូកចែវជាដើម
ហើយទូកនីមួយៗគឺមានសមាជិក ឬក៏ចំណុះទូកជាច្រើននាក់ផងដែរ អ្នកអុំទូក ឬក៏អ្នកចែវទូក
ដែលនៅលើទូក យើងហៅថាចំណុះទូក អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញមានទូកពីរ
ដែលទូកមួយពាក់អាវក្រហម និងទូកមួយទៀត អ្នកអុំទូកគឺគាត់ពាក់អាវលឿង
ដោយអ្នកពាក់អាវក្រហម និងអ្នកពាក់អាវលឿង
គឺមានមនុស្សជាច្រើនកំពុងតែធ្វើការអុំទូកប្រណាំងគ្នា ដែលយើងឃើញមានមនុស្សម្នាក់នៅខាងមុខ
កំពុងតែរាំ យើងហៅថាអ្នករាំក្បាលទូក អញ្ចឹងជាទូទៅទូកប្រណាំងតែងតែមានអ្នករាំក្បាលទូកមួយ
ដែលរាំនៅលើទូកនោះ ហើយបញ្ជាទៅដល់កូនក្រុមទាំងអស់ ឲ្យអុំឬក៏ចែវឲ្យស្រុះៗគ្នា
ដើម្បីបង្កើនល្បឿនទូក អញ្ចឹងជាទូទៅចំណុះទូកនីមួយៗ ឬក៏អ្នកអុំទូកនីមួយៗ
នៅក្នុងមួយទូកមានចំណុះពី ៥០ នាក់ ទៅ ៦០ នាក់ យ៉ាងតិច អញ្ចឹងគឺចំណុះទូកគឺច្រើនណាស់
បានន័យថាទូកប្រណាំងគឺវែង វែងជាងទូកធម្មតា ឆ្ងាយណាស់ គឺមានចំណុះមនុស្ស គឺរហូតដល់
៥០ នាក់ ទៅ ៦០ នាក់ឯណោះ ហើយរួមទាំងអ្នករាំក្បាលទូកម្នាក់ផងដែរ ដែលជាអ្នកបញ្ជា
អញ្ចឹងអ្នកកូនក្រុមទាំងអស់ ឬក៏ចំណុះទូកទាំងអស់ ត្រូវតែស្ដាប់តាមអ្នករាំក្បាលទូក
ដែលបានបញ្ជាទៅលើអ្នកទាំងអស់នោះ ដើម្បីឲ្យបង្កើនល្បឿនទូកទៅដល់ទីជ័យជំនះមុនគេ
ហើយអ្នកដែលអុំទូកទៅដល់ទីជ័យជំនះមុនគេ គឺតែងតែមានរង្វាន់លើកទឹកចិត្តផងដែរ
ដូច្នេះហើយទើបមានទូកជាច្រើន តែងមកតម្រៀបគ្នា ដើម្បីរង់ចាំពិធីបុណ្យអុំទូកជារៀងរាល់ឆ្នាំ
ហើយពិធីបុណ្យអុំទូកគេធ្វើឡើងយ៉ាងសប្បាយរីករាយខ្លាំងណាស់ នៅខាងមុខព្រះបរមរាជវាំង។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩ គឺជាស្តង់តាំងពិព័ណ៌ អញ្ចឹងជារៀងរាល់ឆ្នាំ នៅក្នុងពិធីបុណ្យអុំទូក គឺយើងតែងតែមានពិធីតាំងពិព័ណ៌ផងដែរ ដោយជាទូទៅគឺមានផលិតផលជាច្រើន យកតាមខេត្តនីមួយៗមកតាំងពិព័ណ៌ នៅខាងមុខព្រះបរមរាជវាំង ក៏ដូចជាមកតាំងពិព័ណ៌នៅសួនកម្សាន្តនានា ព្រោះថាពិធីនេះ គឺមានមនុស្សជាច្រើន ដែលមកពីជុំវិញប្រទេស បានន័យថាមកពីបណ្តាខេត្តនានាទាំង ២៥ ខេត្តក្រុង គឺនឹងចូលរួមនៅក្នុងទីក្រុងភ្នំពេញ ឬក៏រាជធានីភ្នំពេញ ដូច្នេះហើយមនុស្សជាច្រើន គឺនឹងមកទីក្រុងភ្នំពេញ អញ្ចឹងការតាំងពិព័ណ៌ គឺជាការផ្សាយពាណិជ្ជកម្មអំពីផលិតផលរបស់ខ្លួន ដើម្បីឲ្យអតិថិជនស្គាល់ ដូច្នេះហើយអ្នកអាជីវករនីមួយៗ តែងតែយកផលិតផលរបស់ខ្លួន មកធ្វើការដាក់តាំងបង្ហាញនិងលក់នៅថ្ងៃបុណ្យអុំទូក ដោយនៅក្នុងរូបភាពនេះ យើងឃើញមានស្តង់លក់ជាច្រើន ដែលស្តង់លក់ជាច្រើននោះ គឺកំពុងតែលក់ផលិតផលរបស់ខ្លួន ដូចជាយើងឃើញនៅខាងឆ្វេងគេ គឺមានបុរសម្នាក់កំពុងតែឈរនៅជិតស្តង់គាត់ ដែលនៅក្នុងនោះគាត់មានលក់ដូចជាឆ្នាំង ចាន ហើយគាត់ឈរលក់នៅខាងមុខស្តង់ ហើយគាត់កំពុងតែហៅអតិថិជនឲ្យចូលមើលផលិតផលរបស់គាត់ ដែលនៅជាប់នោះ គឺមាននារីម្នាក់ ឬក៏ស្ត្រីម្នាក់ គាត់កំពុងតែឈរលក់ឆ្នាំងចានដូចគ្នា អញ្ចឹងជួរស្តង់នេះ គឺជាជួរស្តង់ដែលលក់ឆ្នាំងចាន ជាទូទៅការតាំងពិព័ណ៌ តែងតែបែងចែកនូវប្រភេទផលិតផលឲ្យលក់នូវក្នុងតំបន់ផ្សេងៗគ្នា ដូចជាចំណីអាហារ គេលក់មួយផ្នែក ឆ្នាំងចានលក់មួយផ្នែក និងខោអាវលក់មួយផ្នែក ហើយជាទូទៅផលិតផលទាំងអស់ គឺយកមកតាមខេត្តនីមួយៗ ដែលយើងហៅថា ខេត្តមួយផលិតផលមួយ អញ្ចឹងជាទូទៅ ២៥ ខេត្តក្រុងត្រូវតែមានផលិតផលរៀងៗខ្លួន ដើម្បីយកមកតាំងពិព័ណ៌នៅក្នុងថ្ងៃពិធីបុណ្យអុំទូក។

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ គឺយើង គេការបង្ហាញសិល្បៈ នៃការរាំក្បាច់ប្រពៃណីខ្មែរ អញ្ចឹងនៅក្នុងពិធីបុណ្យអុំទូក ក្រៅពីការអុំទូក ក្រៅពីការបណ្តែតប្រទីប ហើយនិងក្រៅពីការតាំងពិព័ណ៌និងប្រគំតន្ត្រី គឺយើងតែងតែមានសម្តែងសិល្បៈផ្សេងៗ ដូចជាការរាំរបាំប្រពៃណី ការលេងល្បែងប្រពៃណី ការច្រៀងចម្រៀងអាយ៉ៃ ការច្រៀងចម្រៀងចាប៉ីដងវែងជាដើម ដែលសុទ្ធតែជាសិល្បៈប្រពៃណីវប្បធម៌របស់ខ្មែរ អញ្ចឹងថ្ងៃបុណ្យអុំទូក គឺយើងបង្ហាញអំពីវប្បធម៌របស់ខ្មែរទាំងអស់ តាំងពីបុរាណមក ដែលជាក់ស្តែងនៅក្នុងរូបភាពនេះ គឺមាននារីមួយក្រុមកំពុងតែរាំសិល្បៈ ឬក៏រាំក្បាច់របាំអប្សរានៅលើឆាក ដើម្បីឲ្យទស្សនិកជនមើល អញ្ចឹងរបាំអប្សរា គឺជារបាំដ៏ពិសេសមួយ របស់ប្រទេសកម្ពុជា ដែលមានវយចំណាស់យូរលង់ណាស់មកហើយ ហើយគេតែងតែរាំរបាំនេះ នៅក្នុងពិធីធំៗផ្សេងៗ ដូចជាពិធីបុណ្យចូលឆ្នាំ ពិធីបុណ្យអុំទូកជាដើម អញ្ចឹងនៅពេលដែលមានពិធីបុណ្យផ្សេងៗ យើងតែងតែបង្ហាញរបាំអប្សរានេះ ទៅដល់ទស្សនិកជន

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយយើងឃើញនៅក្នុងរូបភាពនេះគឺនារីមួយក្រុមកំពុងតែរាំនៅលើឆាក ឬក៏វេទិកាមួយ
ដែលរាំទៅតាមភ្លេង អញ្ចឹងគេមានចាក់ភ្លេងរបាំ ហើយនារីរបាំរាំទៅតាមភ្លេងនោះ
ដែលមានទស្សនិកជនជាច្រើន ដែលនៅខាងក្រោមឆាក កំពុងតែឈរទះដៃនិងអបអរសាទរ
ទៅដល់ក្រុមនារីរបាំនោះ ដែលយើងឃើញនៅក្នុងរូបភាពនេះ គឺនារីរបាំមានស្លៀកពាក់ឈុត
ដូចជាពណ៌ខៀវ ពណ៌បៃតង ពណ៌ទឹកក្រូចជាដើម ជាទូទៅការរាំរបាំគឺតែងតែស្លៀកពាក់ឈុត
ទៅតាមពណ៌ ទៅតាមថ្ងៃនីមួយៗ ដែលនៅក្នុងប្រទេសកម្ពុជា គឺវប្បធម៌របស់យើង
គឺតែងតែមានបែងចែកពណ៌ទៅតាមថ្ងៃទាំងប្រាំពីរថ្ងៃ បានន័យថាប្រាំពីរថ្ងៃគឺយើងស្លៀកប្រាំពីរពណ៌
អញ្ចឹងនៅក្នុងរូបភាពនេះគឺនារីរបាំ គាត់ស្លៀកពាក់សំពត់ទៅតាមពណ៌របស់ថ្ងៃ ដូចជាពណ៌ទឹកក្រូច
ពណ៌លឿង និងពណ៌បៃតងជាដើម។ អញ្ចឹងគាត់កំពុងតែសម្តែងរបាំទៅដល់ទស្សនិកជន
នៅក្នុងថ្ងៃបុណ្យអុំទូក។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ គឺជារូបភាពនៃការបណ្តែតប្រទីប អញ្ចឹងជាទូទៅ
នៅក្នុងព្រះរាជពិធីបុណ្យអុំទូករយៈពេលបីថ្ងៃ គឺយើងតែងតែមានប្រារព្ធពិធីបណ្តែតប្រទីបផងដែរ
ដែលប្រទីបនៅក្នុងប្រទេសកម្ពុជា គឺបែងចែកចេញជាពីរ គឺប្រទីបធំនិងប្រទីបតូច
ដែលប្រទីបធំគឺជាប្រទីបដែលរៀបចំដោយរដ្ឋាភិបាល អញ្ចឹងក្រសួងនីមួយៗ
ដែលចំណុះឲ្យរដ្ឋាភិបាល ត្រូវតែមានប្រទីបមួយៗ ដែលតាំងភ្លើង
និងបង្ហាញអំពីនិមិត្តសញ្ញារបស់ក្រសួងខ្លួនឯង ដើម្បីប្រាប់ទៅដល់ប្រជាជនទាំងអស់ឲ្យបានដឹង
ដោយប្រទីបធំ គឺយើងមានតាំងអំពូលភ្លើងជាច្រើន ចម្រុះពណ៌ ដែលមើលទៅគួរឲ្យស្រស់ស្អាត
ដែលមើលទៅស្រស់ស្អាត ហើយបណ្តែតនៅលើទន្លេមុខព្រះបរមរាជវាំង
ដែលជាទូទៅយើងបណ្តែតប្រទីបនៅពេលយប់ ហើយប្រទីបមួយប្រភេទទៀតគឺជាប្រភេទតូច
ដែលយើងឃើញនៅក្នុងរូបភាពនេះ គឺជាប្រទីបដែលបណ្តែតដោយប្រជាជន
នៅក្នុងការផ្សងបំណងប្រាថ្នានានា អញ្ចឹងបំណងប្រាថ្នានានានៅក្នុងថ្ងៃបុណ្យអុំទូក
ប្រជាជនតែងតែបណ្តែតប្រទីប ដែលប្រទីបនោះធ្វើអំពីធាងចេក ហើយនិងស្លឹកចេក
បន្ទាប់មកយើងដាក់បាយចំណីនៅលើប្រទីបនោះ ហើយយើងបានអុជទៀនមួយដើម
នៅលើប្រទីបនោះ រួចបណ្តែតទៅតាមខ្សែទឹក អញ្ចឹងទឹកទន្លេគឺជាទឹកហូរ
ដូច្នេះនៅពេលដែលយើងបណ្តែតប្រទីប គឺយើងឲ្យវាហូរទៅតាមទឹក
អញ្ចឹងប្រជាជនកម្ពុជាគឺមានជំនឿថា នៅពេលដែលយើងបណ្តែតប្រទីប
គឺនឹងបំណងប្រាថ្នារបស់យើង នឹងបានសម្រេច ព្រោះថាប្រទីបនោះ
នឹងជួយឲ្យបំណងប្រាថ្នារបស់យើងបានសម្រេច។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី ១២ គឺនៅពេលយប់
អញ្ចឹងនៅពេលយប់នៅក្នុងថ្ងៃបុណ្យអុំទូក ឬក៏ថ្ងៃនៃប្រារព្ធពិធីបុណ្យអុំទូក
គឺតែងតែមានការបាញ់កាំជ្រួច អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ គឺមានកាំជ្រួចតូចធំជាច្រើន
កំពុងតែបាញ់ទៅលើអាកាស អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញមានផ្ទះ
និងមានដើមឈើជាច្រើន ដែលបានន័យថានៅក្នុងភូមិមួយ ឬក៏នៅក្នុងស្រុកមួយ
ហើយគេប្រារព្ធពិធីបាញ់កាំជ្រួចនៅពេលយប់ អញ្ចឹងកាំជ្រួចគឺគេបាញ់នៅពេលយប់តែប៉ុណ្ណោះ
ព្រោះថាពេលថ្ងៃយើងមើលអត់ឃើញទេ ភ្លឺពេកគឺមើលអត់ឃើញទេ
ក៏ប៉ុន្តែនៅពេលដែលយើងបាញ់ពេលយប់ គឺយើងមើលឃើញច្បាស់ ហើយស្អាត
ព្រោះកាំជ្រួចគឺជាភ្លើងពណ៌ផ្សេងៗ ដែលបាញ់ហោះទៅលើអាកាស នៅពេលដែលវាផ្ទុះ
គឺវាចេញផ្កាភ្លើងពណ៌ផ្សេងៗ ទៅតាមការរៀបចំរបស់អ្នកផលិតកាំជ្រួច ដែលយើងមើលទៅ
គឺស្រស់ស្អាតនៅលើផ្ទៃមេឃតែម្តង បានន័យថាពន្លឺកាំជ្រួចគឺស្រស់ស្អាត
ក៏ប៉ុន្តែវាក៏មានគ្រោះថ្នាក់ផងដែរ ប្រសិនបើយើងចូលទៅជិតកាំជ្រួច នៅពេលដែលកាំជ្រួចផ្ទុះ
វាអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់យើង រហូតដល់គ្រោះថ្នាក់ដល់អាយុជីវិត
អញ្ចឹងយើងអត់ត្រូវចូលទៅជិតកាំជ្រួចនោះទេ យើងមើលពីចម្ងាយ យើងអត់ត្រូវចូលជិតកាំជ្រួចទេ
ព្រោះវានាំឲ្យមានគ្រោះថ្នាក់ ប៉ុន្តែនៅពេលដែលយើងមើលពីចម្ងាយ
នៅពេលដែលកាំជ្រួចហោះឡើង ហើយវាផ្ទុះ គឺធ្វើឲ្យមានភាពស្រស់ស្អាតនៅលើផ្ទៃអាកាស
អញ្ចឹងយើងតែងតែបាញ់កាំជ្រួច ដើម្បីអបអរថ្ងៃពិធីបុណ្យចូលឆ្នាំថ្មី ក៏ដូចជាពិធីបុណ្យអុំទូកជាដើម
ដែលនៅក្នុងរូបភាពនេះ គេកំពុងតែបាញ់កាំជ្រួច ដើម្បីអបអរពិធីបុណ្យអុំទូក។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ គឺបន្ទាប់ពីពិធីបុណ្យអុំទូករួចរាល់ហើយ
វាគឺជារដូវសម្រក ដែលជាទូទៅប្រជានេសាទ ដែលយើងហៅថាអ្នកប្រកបរបរនេសាទត្រី ឬក៏ចាប់ត្រី
យើងហៅថាប្រជានេសាទ អញ្ចឹងអ្នកនេសាទទាំងអស់ គឺចាប់ផ្តើមរបររបស់ខ្លួន
ដោយចាប់ផ្តើមទៅនេសាទត្រី អញ្ចឹងពួកគាត់ចាប់ត្រីនៅក្នុងទន្លេ អញ្ចឹងការចាប់ត្រី
យើងអាចហៅថាពីរ ហៅបានពីរ គឺចាប់ត្រី ឬក៏នេសាទត្រី អញ្ចឹងជាទូទៅឧបករណ៍ចាប់ត្រី
គឺយើងតែងតែមាន អញ្ចឹងនៅក្នុងប្រទេសកម្ពុជាគឺមានឧបករណ៍ចាប់ត្រីផ្ទាល់ខ្លួនរបស់ខ្លួនតែម្តង
ដោយប្រជាជនកម្ពុជាបង្កើតឧបករណ៍ចាប់ត្រីផ្ទាល់ខ្លួន យើងហៅថាឧបករណ៍ប្រពៃណី
គឺមានដូចជាមង មានដូចជាអួន មានដូចជាទ្រូ មានដូចជាលបជាដើម
អញ្ចឹងយើងប្រើប្រាស់ឧបករណ៍ទាំងអស់នេះ ដើម្បីចាប់ត្រីនៅក្នុងទន្លេ
ដែលជាក់ស្តែងនៅក្នុងរូបភាពនេះ គឺមានបុរសម្នាក់ កំពុងតែបង់សំណាញ់ ឬក៏បង់មង
ចូលទៅក្នុងទន្លេ ដើម្បីចាប់ត្រី ដោយសំណាញ់នោះគឺជាខ្សែនីឡុង យើងធ្វើមកពីខ្សែនីឡុង
ហើយក្រងវាទៅជាសំណាញ់ ដែលខាងចុងសំណាញ់នោះ គឺមានបង្កប់ដោយដែក

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងនៅពេលដែលបោះចូលទៅក្នុងទឹក វានឹងធ្លាក់ចុះទៅក្រោម
ដូច្នេះនៅពេលដែលទាញឡើងមកវិញ គឺវានឹងជាប់ត្រីនៅក្នុងនោះ អញ្ចឹងហើយ រូបភាពនេះ
គឺយើងឃើញមានបុរសម្នាក់ ដែលជាអ្នកនេសាទ គាត់កំពុងតែបោះសំណាញ់ ឬក៏បោះមងរបស់គាត់
ចូលទៅក្នុងទន្លេ ដើម្បីនេសាទត្រី ដោយថ្ងៃនេះគឺជារដូវវស្សា រដូវប្រាំង
ដោយសារតែថ្ងៃនេះគឺជារដូវប្រាំង ដូច្នេះយើងឃើញផ្ទៃមេឃស្រឡះ មានពពកសតូចៗជាច្រើន
កំពុងតែរសាត់នៅលើមេឃ ហើយព្រះអាទិត្យកំពុងតែបញ្ចេញពន្លឺយ៉ាងត្រចះត្រចង់
ដូច្នេះហើយវាជា គឺជារដូវសម្រក អញ្ចឹងអ្នកនេសាទទាំងអស់ចាប់ផ្ដើមរបរនេសាទរបស់ខ្លួន
នៅតាមដងទន្លេនានា អញ្ចឹងជាទូទៅនៅពេលដែលរដូវសម្រក យើងមើលឃើញទៅតាមទន្លេ
គឺសុទ្ធតែអ្នកនេសាទទាំងអស់ ដែលមានទូកតូចធំជាច្រើន មកនេសាទត្រីនៅលើផ្ទៃទឹក។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.